ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០...................សហវ.ប្រក

ថ្ងៃ ............ ខែ ............ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០២២.

# សេចក្ដីសម្រេច
## ស្ដីពី
## ការកែសម្រួលសមាសភាពអនុគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ខេត្តមណ្ឌលគិរី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ និងវិសោធនកម្មបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២២៤ ប្រក.សហវ.ពដ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៦ ស្ដីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ៧៨៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ ខេត្តមណ្ឌលគិរី

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ (+៨៥៥)២៣ ៨៩០ ៦៦៦
Phone : (+855)23 890 666

## សម្រេច

**ប្រការ ១.-**

ត្រូវបានកែសម្រួលសមាសភាពអនុគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ខេត្តមណ្ឌលគិរី ដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ថង សាវុន** | អភិបាល នៃគណៈអភិបាលខេត្ត | ប្រធាន |
| ២. | លោក **ម៉េង សម្បត្តិ** | អភិបាលរង នៃគណៈអភិបាលខេត្ត | អនុប្រធាន |
| ៣. | លោក **ឈឹម គាន** | អភិបាលរង នៃគណៈអភិបាលខេត្ត | អនុប្រធាន |
| ៤. | លោក **អ៊ុង តិចណារិញ** | ប្រធានសាខាពន្ធដារខេត្ត | អនុប្រធានប្រចាំការ |
| ៥. | លោក **ម៉ៅ ចំរើន** | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | អនុប្រធាន |
| ៦. | លោក **ស៊ីន សារុន** | នាយករដ្ឋបាលសាលាខេត្ត | សមាជិក |
| ៧. | លោក **ឡឿង ផៃរិទ្ធិ** | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ៨. | លោក **សុខ ឃាង** | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត | សមាជិក |
| ៩. | ឯកឧត្តម **ឡៅ សុថា** | ប្រធានសាលាដំបូងខេត្ត | សមាជិក |
| ១០. | លោក **កែវ សុគតិ** | ប្រធានមន្ទីរបរិស្ថានខេត្ត | សមាជិក |
| ១១. | លោក **រស់ គីមឃន** | ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្ត | សមាជិក |
| ១២. | **លោកអភិបាល នៃគណៈអភិបាល គ្រប់ក្រុង/ស្រុក** | | សមាជិក |
| ១៣. | លោក **សាន តី** | អនុប្រធានសាខាពន្ធដារខេត្ត | សមាជិក |
| ១៤. | លោក **យឹម វណ្ណា** | អនុប្រធានមន្ទីរ ជ.ន.ស.ស ខេត្ត | សមាជិក |
| ១៥. | **លោកប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង/ស្រុក គ្រប់ស្រុក** | | សមាជិក |
| ១៦. | លោកស្រី **រិន ដាណេ** | ប្រធានការិយាល័យសេវាអ្នកជាប់ពន្ធ នៃសាខាពន្ធដារខេត្ត | សមាជិក |

**ប្រការ ២.-**

អនុគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ មានភារកិច្ច ដូចខាងក្រោម ÷

- ផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បង្កើតបញ្ជីដីត្រូវជាប់ពន្ធតាមតំបន់ក្នុងខេត្ត
- លើកគម្រោងតម្លៃដីក្នុងមួយម៉ែត្រក្រឡា គិតតាមតំបន់នីមួយៗក្នុងខេត្ត ដើម្បីជាមូលដ្ឋានគណនាប្រាក់ពន្ធ ដាក់ជូនគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ពិនិត្យ និងសម្រេច
- ផ្តល់មតិចំពោះរឿងវិវាទនានា ដែលពាក់ព័ន្ធទៅនឹងដីមិនបានប្រើប្រាស់។

**ប្រការ ៣.-**

អនុគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ អាចរៀបចំបង្កើតក្រុមជំនួយការមួយ ដើម្បីធានានិរន្តរភាពក្នុងប្រតិបត្តិការរបស់អនុគណៈកម្មការ។

**ប្រការ ៤.-**

សមាជិកអនុគណៈកម្មការ ត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានអនុគណៈកម្មការ។

**ប្រការ ៥.-**

អនុគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានគណៈកម្មការ និងត្រូវរាយការណ៍ជាប្រចាំតាមខែនីមួយៗ មកគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់។

**ប្រការ ៦.-**

សេចក្តីសម្រេចណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧.-**

ឯកឧត្តម អស់លោក លោកស្រី ដែលជាសមាសភាពដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**ប្រធានគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់**

**បណ្ឌិតសភាចារ្យ ជួ ចិនិត្ត**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តមណ្ឌលគិរី
  "ដើម្បីជូនជ្រាប និងសហការ"
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ